**Declassified to Public**
**12 June 2020**

លេខ៖ D193/67

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 05 / 05 / 2016
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចលុបចោលការកោសលុបពីឯកសារសំណុំរឿង ០០៤ ដែលបានដាក់បញ្ចូល ក្នុងសំណុំរឿង ០០២

__ផ្ញើជូន៖__

សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូង

ជា លាង

Nicholas KOUMJIAN

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ចៅ.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

២. ចាប់តាំងពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៣ មក អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលខ្ញុំជំនួសតំណែង បានឯកភាពឱ្យដាក់បង្ហាញឯកសារមួយចំនួនពីសំណុំរឿង ០០៤ ចូលក្នុងសំណុំរឿង ០០២ ដោយសារថា ឯកសារទាំងនោះជាប់ពាក់ព័ន្ធនឹងបញ្ហានានានៅក្នុងដំណើរការជំនុំជម្រះដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០២។ ដោយគិតពីដំណាក់កាលស៊ើបសួរ និងលក្ខណៈនៃឯកសារដែលបានដាក់បង្ហាញ ទើបអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្កើតការដាក់កំហិត និងទម្រង់បែបបទមួយចំនួនសម្រាប់ការដាក់បង្ហាញឯកសារចម្លើយទាំងនេះជូនទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីនៅក្នុងសំណុំរឿង ០០២។ ឯកសារមួយក្នុងចំណោមឯកសារទាំងនេះ គឺជាសំណៅកោសលុបដែលចាត់ទុកថាមានលក្ខណៈរសើបដល់កិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការ ឬជាព័ត៌មានដែលចាត់ទុកថាមិនជាប់ពាក់ព័ន្ធនឹងភស្តុតាងដែលស្វែងរកទេ។

៣. នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាសម្រេចលុបចោលការកោសលុបលើសាក្សីភាគច្រើន និងឯកសារពួកគាត់ដែលបានដាក់បង្ហាញ ដោយសារថា លែងមានតម្រូវការចាំបាច់ត្រូវធ្វើការកោសលុបដើម្បីរក្សាសុចរិតភាពនៃកិច្ចស៊ើបសួរទៀតហើយ[1]។

៤. ខ្ញុំក៏បានត្រួតពិនិត្យមើលឯកសារនៅសេសសល់ដែលបានដាក់បង្ហាញក្នុងទម្រង់កោសលុប ហើយយល់ឃើញថា ឯកសារទាំងអស់ក្រៅពីឯកសារចំនួនបី(D134/3, D219/466 និង D219/466.1) គឺលែងត្រូវការកោសលុបដើម្បីរក្សាសុចរិតភាពនៃកិច្ចស៊ើបសួរទៀតហើយ។

៥. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

---

[1] សំណុំរឿង០០៤ ឯកសារ D193/66 *ដីកាសម្រេចលុបចោលការកោសលុបពីឯកសារសំណុំរឿង ០០៤ ដែលបានដាក់ចូលក្នុងសំណុំរឿង ០០២* ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៦. **អនុញ្ញាតឲ្យ**ដាក់បង្ហាញជូនទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីនៅក្នុងសំណុំរឿង ០០២ នូវឯកសារ D219/125 ជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី សឿម ក្នុងទម្រង់ជាឯកសារពេញលេញ និងគ្មានការកោសលុប។

៧. **ដាក់** ស្រី សឿម ក្នុង**សាក្សីប្រភេទ** ក ស្របតាមវិធានការដែលបានបង្ហាញនៅក្នុងអនុស្សរណៈចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥[2]។ ដោយសារលក្ខណៈសម្ងាត់ និងរសើបនៃការស៊ើបអង្កេតដែលកំពុងបន្តដំណើរការ ទើបការដាក់បង្ហាញនេះត្រូវបានអនុញ្ញាតក្នុងទម្រង់បែបបទ និងមានការដាក់កំហិតដូចខាងក្រោម៖

(ក) រាល់ឯកសារទាំងអស់ដែលផ្តល់ជូនពីសំណុំរឿង ០០៤ ត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

(ខ) ក្នុងករណីដែលឯកសារដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង ០០២ នោះ ឯកសារនេះត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

(គ) គ្មានឯកសារណាដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវផ្សព្វផ្សាយឱ្យហួសពីអ្វីដែលបានកំណត់យ៉ាងច្បាស់នៅក្នុងដីកាសម្រេចនេះឡើយ។

(ឃ) ក្នុងករណីដែលសាក្សីដែលឯកសារគាត់ ត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញ ហើយត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មនោះ គាត់អាចផ្តល់សក្ខីកម្មបាននៅក្នុងសវនាការសាធារណៈ ដរាបណាឈ្មោះ និងអត្តសញ្ញាណរបស់គាត់រក្សាការសម្ងាត់។

(ង) ភាគី មេធាវី ឬបុគ្គលផ្សេងទៀតណាក៏ដោយដែលអាន ដកស្រង់ ឬក៏ប្រើប្រាស់ឯកសារដែលបានដាក់បង្ហាញនេះ ត្រូវតែបង្ហាញអត្តសញ្ញាណសាក្សី តែតាមរយៈ

---

[2]សំណុំរឿង០០៤ ឯកសារ D273 *អនុស្សរណៈពី ស.ច.ស.អ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹង"ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅសំណុំរឿង ០០២"* ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០១៥។

រហស្សនាមដែលគេដាក់ឱ្យគាត់តែប៉ុណ្ណោះសម្រាប់សំណុំរឿង០០២ ហើយ ប្រើប្រាស់ការពិពណ៌នានាដែលផ្សព្វផ្សាយឱ្យបានសមហេតុផល ដើម្បីចៀសវាង បង្ហាញអត្តសញ្ញាណសាក្សីតាមរយៈព័ត៌មានផ្សេងទៀត។

(ច) គ្មានឯកសារណាដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវផ្សព្វផ្សាយដល់ សាធារណជន ក្នុងទម្រង់ណាមួយ ឬតាមរយៈរូបភាពណាមួយនៃប្រព័ន្ធផ្សព្វផ្សាយ អ្វីក៏ដោយ ដែលហួសពីភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការសាធារណៈ។

(ឆ) ឯកសារដែលអនុញ្ញាតឱ្យដាក់បង្ហាញនេះ ត្រូវផ្តល់ជូនទៅក្រុមមេធាវីការពារក្តីរបស់ ជនជាប់ចោទទាំងពីរ មេធាវីប្រចាំការរបស់ ខៀវ សំផន (“មេធាវីប្រចាំការ”) និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈសំណៅអេឡិចត្រូនិច។

ជ) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវ បង្ហាញឯកសារដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ឱ្យទៅតែសមាជិកណា នៅក្នុងក្រុមការងាររបស់ខ្លួនដែលទទួលបានការងារជាផ្លូវការតាមវិធានផ្ទៃក្នុង ២២ (៥)និង១២*ស្ទួនពីរ*(៤) ព្រមទាំងកម្មសិក្សាការីដែលទទួលបានការចាត់តាំងផ្លូវការតែ ប៉ុណ្ណោះ។

(ឈ) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មិន ត្រូវបានអនុញ្ញាតឱ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ថតចម្លងសំណៅ ឯកសារដើមក្រៅពីគោលបំណងប្រើប្រាស់ផ្ទៃក្នុងដែលបានផ្តល់ជូនខ្លួនពីសមាជិក ក្រុមការងាររបស់ខ្លួន ដែលត្រូវបានណែនាំ ឬអនុញ្ញាតឱ្យចូលពិនិត្យមើលឯកសារ សម្ងាត់។

(ញ) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាទុកកំណត់ហេតុនៃសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ថតចម្លងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង គឺត្រូវរក្សាទុកក្នុងរបៀបមួយដែលអាច ត្រួតពិនិត្យឡើងវិញបាន។

(ដ) ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង

01238527



០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតឱ្យដាក់បង្ហាញណាមួយក្នុងចំណោម ឯកសារដែលបានអនុញ្ញាតឱ្យដាក់បង្ហាញនោះ គាត់ត្រូវចាត់គ្រប់វិធានការភ្លាមៗ ដើម្បីរក្សាសុវត្ថិភាពសំណៅនោះ និងប្រគល់សំណៅនោះជូន ស.ច.ស វិញ។

(ឋ) ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កំហិតទាំងនេះ គាត់ត្រូវរាយការណ៍ការរំលោភបំពានបែបនេះជូន ស.ច.ស។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**